# BRIEFING NOTES

UNITED NATIONS
HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

**អ្នកនាំពាក្យរបស់ឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស៖** អ្នកស្រី រ៉ាវីណា សេមសាដានី (Ravina Shamdasani)

**ទីតាំង៖** ទីក្រុងហ្សឺណែវ

**កាលបរិច្ឆេទ៖** ថ្ងៃសុក្រទី១១ ខែឧសភា ឆ្នាំ២០១៨

## កំណត់សង្ខេបស្តីពីប្រទេសកម្ពុជា

យើងមានការខកចិត្តចំពោះសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍របស់ប្រទេសកម្ពុជា ដែលបានធ្វើឡើងកាលពីថ្ងៃម្សិលមិញ ដោយធ្វើការតម្កល់សេចក្តីសម្រេចផ្តន្ទាទោសសមាជិក និងអ្នកគាំទ្រគណបក្សប្រឆាំងចំនួន ១១ រូប ពីបទ«កុបកម្ម» បើទោះបីជាមានកង្វល់អំពីសិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ និងទស្សនៈយល់ឃើញទៅលើការជ្រៀតជ្រែករបស់រដ្ឋាភិបាលនៅក្នុងរយៈពេលនៃការជំនុំជម្រះក៏ដោយ។

បុរសទាំងនោះដែលជាសមាជិក និងអ្នកគាំទ្រគណបក្សសង្គ្រោះជាតិ ត្រូវបានផ្តន្ទាទោសដំបូងនៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៥ ឲ្យជាប់ពន្ធនាគារពី ៧ ឆ្នាំ ទៅ ២០ ឆ្នាំ ទាក់ទងនឹងអំពើហិង្សាដែលបានកើតឡើងនៅក្នុងអំឡុងពេលធ្វើបាតុកម្មនៅឯទីលានប្រជាធិបតេយ្យ ក្នុងរាជធានីភ្នំពេញ នាថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤។

ការិយាល័យសិទ្ធិមនុស្សរបស់ អ.ស.ប ប្រចាំប្រទេសកម្ពុជា បានឃ្លាំមើលសវនាការជំនុំជម្រះក្តីទាំងនៅសាលាដំបូង ទាំងនៅសាលាឧទ្ធរណ៍។ បើទោះជាសវនាការនៅសាលាឧទ្ធរណ៍បានដំណើរការត្រឹមត្រូវតាមនីតិវិធីក្តី ក៏សវនាការនេះមិនបានដោះស្រាយភាពខ្វះចន្លោះទាក់ទងនឹងការជំនុំជម្រះប្រកបដោយយុត្តិធម៌ ហើយដែលបានជះឥទ្ធិពលមិនល្អដល់សេចក្តីសម្រេចផ្តន្ទាទោសរបស់សាលាដំបូងនាពេលនោះ។ នៅក្នុងអំឡុងពេលសវនាការនៅសាលាដំបូង ជនជាប់ចោទមិនអាចសួរសំណួរតទល់ទៅដើមបណ្តឹង ហើយក៏មិនត្រូវបានគេផ្តល់ពេលវេលាគ្រប់គ្រាន់ និងឱកាសដើម្បីបង្ហាញមធ្យោបាយការពារខ្លួនដែរ។ ចំណុចទាំងនេះបានបង្កើតឱ្យមានការសង្ស័យពាក់ព័ន្ធនឹងការធានាឱ្យមានការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងសមភាពនៃការតទល់គ្នាតាមផ្លូវតុលាការ។ នៅក្នុងពេលសវនាការសាលាឧទ្ធរណ៍ ដើមបណ្តឹង (សមាជិកនៃកងកម្លាំងសន្តិសុខដែលជួលដោយរដ្ឋាភិបាល) បានសារភាពថា ពួកគេគ្រាន់តែបានចុះហត្ថលេខាលើពាក្យបណ្តឹងដែលសរសេរឡើងដោយអ្នកដទៃតែប៉ុណ្ណោះ។

បាតុកម្មនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤ បានបញ្ចប់ទៅដោយអំពើហិង្សាគួរឲ្យរន្ធត់ ដោយមានមនុស្សរាប់សិបនាក់បានរងរបួស។ ទោះជាយ៉ាងណាក៏ដោយ ក៏វាមិនមានភ័ស្តុតាងណាមួយ ត្រូវបានបង្ហាញនៅក្នុងអំឡុងពេលជំនុំជម្រះក្តីនៅសាលាដំបូង និងនៅសាលាឧទ្ធរណ៍ ដែលថាបុរសដែលត្រូវតុលាការផ្តន្ទាទោសទាំង១១ នាក់នោះមានការពាក់ព័ន្ធទៅនឹងអំពើ

ហិង្សា ហើយក៏មិនមានភ័ស្តុតាងណាមួយដែលភ្ជាប់ពួកគេទៅនឹងការចោទប្រកាន់ពីបទ«កុបកម្ម»ដែលមានចែងនៅក្នុងច្បាប់ថាជា «អំពើហិង្សាជាសមូហភាព ដែលអាចនាំឲ្យមានគ្រោះថ្នាក់ដល់ស្ថាប័ននៃព្រះរាជាណាចក្រកម្ពុជា ឬនាំឱ្យមានការប៉ះពាល់ដល់បូរណភាពនៃដែនដីជាតិ» ឡើយ។ ទាំងដើមបណ្ដឹងដែលបានរងរបួស ទាំងខ្សែអាត់វីឌីអូដែលថតអំពីឧបទ្ទវហេតុ ហើយដែលត្រូវបានបង្ហាញថាជាភស្តុតាង មិនបានគូសបញ្ជាក់ថាបុរសដែលត្រូវតុលាការផ្តន្ទាទោសទាំងនោះបានប្រព្រឹត្ត ញុះញង់ ឬដឹកនាំអំពើហិង្សាណាមួយឡើយ។

«សមាជិកគណបក្សសង្គ្រោះជាតិទាំង ១១ រូប»នេះ ដែលត្រូវបានជាប់ឃុំអស់រយៈពេលជិត ៣ ឆ្នាំ ទៅហើយ ហាក់ត្រូវបានផ្តន្ទាទោស ដោយសារតែទស្សនៈនយោបាយរបស់ពួកគេ និងដោយសារតែការអនុវត្តសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិរបស់ខ្លួន។

កន្លងមក យើងបានលើកឡើងពីកង្វល់ដែលថារដ្ឋាភិបាលកម្ពុជាកំពុងប្រើប្រាស់ប្រព័ន្ធតុលាការ ដើម្បីបំបិទមាត់គណបក្សប្រឆាំង អង្គការសង្គមស៊ីវិល និងអ្នកមានមតិជំទាស់នានា ។ កង្វល់ស្រដៀងគ្នានេះ ក៏ត្រូវបានលើកឡើងជាយូរមកហើយ ដោយយន្តការអន្តរជាតិផ្សេងៗទៀតផងដែរ ។

**ចប់**

*សម្រាប់**ការសាកសួរព័ត៌មាន** សូមទាក់ទង៖ អ្នកស្រី **លីស ស្រូសែល** (Liz Throssell) តាមរយៈទូរស័ព្ទលេខ៖ (+៤១ ២២ ៩១៧ ៩៤៦៦ ឬ អ៊ីម៉ែល ethrossell@ohchr.org) ឬ អ្នកស្រី **រ៉ាវីណា សេមសាដានី** (Ravina Shamdasani) តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩១៦៩ ឬ អ៊ីម៉ែល rshamdasani@ohchr.org).*

*ឆ្នាំ២០១៨ នេះ គឺជា**ខួបលើកទី៧០ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស** ដែលអង្គការសហប្រជាជាតិបាន អនុម័តនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨។ សេចក្តីប្រកាសជាសកលនេះជាប់លំដាប់ថ្នាក់ពិភពលោក ផ្អែកខាងអត្ថបទដែលត្រូវបានបកប្រែជា ៥០០ ភាសា ដោយផ្អែកលើគោលការណ៍គ្រឹះដែលថា "មនុស្សគ្រប់រូបកើតមកមានសេរីភាព និងសមភាពខាងសេចក្តីថ្លៃថ្នូរនិងសិទ្ធិ"។ គោលការណ៍គ្រឹះនេះ ស្ថិតនៅជាមួយមនុស្សគ្រប់រូប ជារៀងរាល់ថ្ងៃ។ ដើម្បីគោរពខួបលើកទី៧០ នៃឯកសារដែលមានឥទ្ធិពលដ៏វិសេសវិសាលនេះ និងដើម្បីរក្សាគោលការណ៍នេះកុំឲ្យបាត់បង់ យើងសូមស្នើឲ្យមនុស្សគ្រប់រូបនៅលើពិភពលោក **ក្រោកឈរឡើងដើម្បីសិទ្ធិមនុស្ស៖***
*www.standup4humanrights.org.*